ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈស្ថាបត្យករកម្ពុជា
លេខ ០០២ ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី
## ក្រមសីលធម៌ស្ថាបត្យករនៃគណៈស្ថាបត្យករកម្ពុជា

## ប្រធានក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្ដីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ/បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈស្ថាបត្យករកម្ពុជា
- បានទទួលការឯកភាពពីក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជាក្នុងកិច្ចប្រជុំលើកទី១ នាថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣
- យោងតាមតម្រូវការចាំបាច់របស់គណៈស្ថាបត្យករកម្ពុជា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ក្រមសីលធម៌នេះមានគោលបំណងដូចតទៅ៖

- លើកកម្ពស់សីលធម៌ សមត្ថភាព ប្រសិទ្ធភាព និងសេចក្តីថ្លៃថ្នូរក្នុងការប្រតិបត្តិវិជ្ជាជីវៈស្ថាបត្យកម្មរបស់ស្ថាបត្យករ
- ការពារផលប្រយោជន៍សាធារណៈ
- ជំរុញដល់ការអភិវឌ្ឍបច្ចេកទេសទំនើបលើវិស័យស្ថាបត្យកម្ម។

**ប្រការ ២.-**

ក្រមសីលធម៌នេះមានគោលដៅកំណត់អំពីការប្រកបវិជ្ជាជីវៈសម្រាប់ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី គ.ស.ក. ។

**ប្រការ ៣.-**

ក្រមសីលធម៌នេះមានវិសាលភាពអនុវត្តចំពោះស្ថាបត្យករខ្មែរនិងស្ថាបត្យករបរទេសដែលបានចុះឈ្មោះក្នុងបញ្ជីគ.ស.ក. ហើយកំពុងប្រកបវិជ្ជាជីវៈស្ថាបត្យកម្មនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ករណីយកិច្ចស្ថាបត្យករចំពោះវិជ្ជាជីវៈស្ថាបត្យកម្ម

**ប្រការ ៤.-**

ស្ថាបត្យករត្រូវមានមនសិការក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួនដូចខាងក្រោម៖

- ប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរនិងកិត្តិយសក្នុងវិជ្ជាជីវៈដោយទទួលខុសត្រូវទាំងស្រុងទៅលើកិច្ចការ និងរបាយការណ៍ដែលខ្លួនបានធ្វើ
- ប្រកបវិជ្ជាជីវៈឲ្យបានល្អជូនអតិថិជនរបស់ខ្លួនប្រកបដោយភាពជឿជាក់ ស្មោះត្រង់ សុចរិត និងត្រូវគោរពផលប្រយោជន៍របស់សាធារណជនដោយផ្អែកតាមបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- គិតគូរដល់ការអភិវឌ្ឍប្រកបដោយចីរភាពនិងផលប៉ះពាល់ចំពោះសុខភាព សុវត្ថិភាពសាធារណៈ សោភណភាព និងបរិស្ថាន។

**ប្រការ ៥.-**

ស្ថាបត្យករត្រូវអភិវឌ្ឍចំណេះដឹងជំនាញរបស់ខ្លួនជានិច្ចឲ្យបានសមស្របតាមការវិវត្តបច្ចេកទេសនិងបច្ចេកវិទ្យាទំនើបតាមរយៈការចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាលជាបន្តបន្ទាប់។

ប្រការ ៦.

ស្ថាបត្យករអាចផ្សព្វផ្សាយជាសាធារណៈនូវការប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួន ប្រសិនបើការផ្សព្វផ្សាយនោះមានគុណប្រយោជន៍ដល់វិស័យស្ថាបត្យកម្មនិងមិនបង្កឲ្យអាប់ឱនដល់វិជ្ជាជីវៈ ។ ការផ្សព្វផ្សាយដែលបង្កឲ្យអាប់ឱនដល់វិជ្ជាជីវៈមានជាអាទិ៍៖

- ការផ្សព្វផ្សាយដែលនាំឲ្យមានការយល់ច្រឡំ
- ការផ្សព្វផ្សាយទិន្នន័យមិនត្រឹមត្រូវ
- ការផ្សព្វផ្សាយក្នុងន័យបោកបញ្ឆោត ឬក្លែងបន្លំ
- ការផ្សព្វផ្សាយទាំងឡាយណាដែលត្រូវបានហាមឃាត់ដោយក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៧.-

ស្ថាបត្យករមិនត្រូវ៖

- ផ្តល់របាយការណ៍លម្អៀង ឬឯកសារក្លែងបន្លំ
- ចូលរួម ឬគាំទ្រអ្នកប្រកបវិជ្ជាជីវៈស្ថាបត្យកម្មដែលមិនស្របច្បាប់
- ប្រើល្បិចកលផ្សេងៗបំផ្លើសហួសសមត្ថភាពជំនាញ បទពិសោធ និងសេវាកម្មរបស់ខ្លួនដល់សាធារណជន។

ប្រការ ៨.-

ស្ថាបត្យករត្រូវចៀសវាងការប្រព្រឹត្តអំពើទាំងឡាយណាដែលអាចធ្វើឲ្យអាប់ឱនដល់វិជ្ជាជីវៈកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ខ្លួនទោះស្ថិតនៅក្រៅក្របខ័ណ្ឌនៃវិជ្ជាជីវៈក៏ដោយ។សកម្មភាពដែលនាំឲ្យអាប់ឱនកិត្តិយសនិងសេចក្តីថ្លៃថ្នូរមានជាអាទិ៍៖

- ការចុះហត្ថលេខា ការបោះត្រាទៅលើគម្រោង គំនូរប្លង់ ម៉ាកែត ឬឯកសារផ្សេងៗដែលខ្លួនមិនបានចូលរួម ឬមិនបានធ្វើផ្ទាល់
- ការសម្រេចចិត្តទាំងឡាយណាដែលធ្វើក្នុងចេតនានាំឲ្យប៉ះពាល់គម្រោង។

## ជំពូកទី៣

## ករណីយកិច្ចស្ថាបត្យករចំពោះស្ថាបត្យករ

ប្រការ ៩.-

ស្ថាបត្យករត្រូវមានទំនាក់ទំនងជាសហភាតរៈល្អជានិច្ចជាមួយនឹងស្ថាបត្យករដទៃទៀត ។ ស្ថាបត្យករដែលមានទំនាស់នឹងគ្នាត្រូវព្យាយាមដោះស្រាយតាមការផ្សះផ្សាដោយសន្តិវិធី ក្នុងករណីចាំបាច់ត្រូវធ្វើតាមរយៈក្រុមប្រឹក្សាវិន័យនៃគណៈស្ថាបត្យករកម្ពុជា ។ ស្ថាបត្យករត្រូវជួយគ្នាទៅវិញទៅមកក្នុងគ្រាមានទុក្ខលំបាក ។

## ប្រការ ១០.-

ស្ថាបត្យករមិនត្រូវ៖

- ជ្រៀតជ្រែក ឬដណ្តើមការងារពីស្ថាបត្យករដទៃទៀត ក្នុងពេលដែលស្ថាបត្យករនោះ និងអតិថិជនកំពុងចរចាចុះកិច្ចសន្យាលើគម្រោង
- ប្រើឥទ្ធិពល ឬសិទ្ធិអំណាចរបស់ខ្លួនដោយបំពានលើស្ថាបត្យករដទៃទៀត ដើម្បីបានទទួលការងារពីម្ចាស់គម្រោង ឬនិយោជក
- បង្ខូចកេរ្តិ៍ឈ្មោះ ឬធុរកិច្ចវិជ្ជាជីវៈរបស់ស្ថាបត្យករដទៃទៀតទោះដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី។

## ប្រការ ១១.-

ស្ថាបត្យករត្រូវគោរពឋានៈ គោរពមងារ និងកិត្តិយសរបស់ស្ថាបត្យករដទៃទៀត។

## ប្រការ ១២.-

ស្ថាបត្យករគប្បីចូលរួមចែករំលែកចំណេះដឹងនិងបទពិសោធទៅឲ្យស្ថាបត្យករដទៃទៀត តាមរយៈការប្រជុំផ្សព្វផ្សាយ ការផ្តល់ចំណេះដឹងដោយផ្ទាល់មាត់ សិក្ខាសាលា វគ្គបណ្តុះបណ្តាល អត្ថបទកាសែត ទស្សនាវដ្តី ។ល។

## ប្រការ ១៣.-

ស្ថាបត្យករត្រូវគោរពនិងទទួលខុសត្រូវចំពោះវិជ្ជាជីវៈរបស់ខ្លួនដោយមិនយកគំនិត ឬចម្លងស្នាដៃរបស់ស្ថាបត្យករដទៃទៀតមកប្រើប្រាស់ ប្រសិនបើគ្មានការអនុញ្ញាតនិងការប្រគល់សិទ្ធិឲ្យប្រើប្រាស់នូវគំនិតទាំងនោះ។

## ប្រការ ១៤.-

ស្ថាបត្យករមិនត្រូវ៖

- ផ្តល់ជាអំណោយ ឬសំណូកដល់បុគ្គលដទៃទៀត ដើម្បីទទួលបានគម្រោង
- ចូលរួមក្នុងការប្រកួតប្រជែងគម្រោងប្លង់ទាំងឡាយណា ដែលមិនសមស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ១៥.-

ស្ថាបត្យករដែលបានចូលរួមក្នុងការប្រកួតប្រជែងគម្រោង ត្រូវចៀសវាងរាល់ជំនួបជាមួយគណៈមេប្រយោគដោយផ្ទាល់ ឬមិនផ្ទាល់មុនពេលប្រកាសលទ្ធផល។

## ប្រការ ១៦.-

ស្ថាបត្យករដែលជាសមាជិករបស់គណៈកម្មការរៀបចំការប្រកួតឬគណៈកម្មការមេប្រយោគ មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងការប្រកួតប្រជែងគម្រោងប្លង់ឡើយ ។

ប្រការ ១៧.-

ស្ថាបត្យករពុំមានសិទ្ធិប្រកាសថាជាស្នាដៃរបស់ខ្លួនលើការសិក្សាគម្រោងដែលខ្លួនមិនបានចូលរួម ឬបានចូលរួមតិចតួច។

ប្រការ ១៨.-

ស្ថាបត្យករអាចសិក្សាគម្រោងប្លង់ជំហានបន្តដែលម្ចាស់គម្រោងប្រគល់ឲ្យបាន លុះត្រាតែម្ចាស់គម្រោងបានបញ្ចប់កិច្ចសន្យាសិក្សាគម្រោងប្លង់ជាលាយលក្ខណ៍អក្សរជាមួយស្ថាបត្យករមុនដែលបានសិក្សាគម្រោងនោះ ។ ក្នុងករណីនេះស្ថាបត្យករដែលទទួលសិក្សាគម្រោងជំហានបន្តជាអ្នកទទួលខុសត្រូវ ។

ប្រការ ១៩.-

ស្ថាបត្យករខ្មែរអាចផ្តល់ព័ត៌មាននិងទិន្នន័យអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដល់ស្ថាបត្យករបរទេសដែលកំពុងសិក្សាគម្រោងប្លង់ និងគ្រោងធ្វើការសាងសង់នៅព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២០.-

ស្ថាបត្យករមិនត្រូវសហការផ្នែកវិជ្ជាជីវៈស្ថាបត្យកម្មជាមួយនឹងស្ថាបត្យករណាដែលគណៈស្ថាបត្យករកម្ពុជាបានលុបឈ្មោះចេញពីបញ្ជី ។

ប្រការ ២១.-

ស្ថាបត្យករត្រូវវាយតម្លៃ ឬធ្វើការសន្និដ្ឋានលើគម្រោងប្លង់របស់ស្ថាបត្យករដទៃទៀតដោយផ្អែកតាមទស្សនទានបទដ្ឋានបច្ចេកទេស និងមិនត្រូវធ្វើតាមអារម្មណ៍ កំណាញ់ចំណូលចិត្តរបស់ខ្លួនឡើយ។

## ជំពូកទី៤
## ករណីយកិច្ចស្ថាបត្យករចំពោះនិយោជក

ប្រការ ២២.-

ស្ថាបត្យករមិនត្រូវ ៖

- បង្ហាញព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធទៅនឹងធុរកិច្ច ឬបច្ចេកវិទ្យារបស់ក្រុមហ៊ុន ឬអង្គភាព ដោយគ្មានការយល់ព្រមពីនិយោជក
- ផ្តល់យោបល់ដែលមិនច្បាស់លាស់ដល់និយោជក ។

## ជំពូកទី៥
## ករណីយកិច្ចស្ថាបត្យករចំពោះអតិថិជន

**ប្រការ ២៣.-**

ស្ថាបត្យករមិនត្រូវ ៖

- បង្ហាញព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធទៅនឹងធុរកិច្ច ឬបច្ចេកវិទ្យារបស់អតិថិជនដោយគ្មានការយល់ព្រមពីអតិថិជន
- ផ្តល់យោបល់អំពីវិជ្ជាជីវៈរបស់ខ្លួនដែលមិនច្បាស់លាស់ ឬដែលមិនមែនជាជំនាញរបស់ខ្លួនដល់អតិថិជន ។

**ប្រការ ២៤.-**

ស្ថាបត្យករអាចចាប់ផ្តើមសិក្សាគម្រោងបានក្នុងករណីដែលរាល់សេវាកម្មរបស់ខ្លួនមានភាពស្របច្បាប់ ស្របតាមបទដ្ឋានស្ថាបត្យកម្ម និងតាមកិច្ចព្រមព្រៀងជាមួយអតិថិជន ។ ប្រសិនបើគ្មានសមត្ថភាព និងលទ្ធភាពបំពេញការងារនេះទេ ស្ថាបត្យករមិនត្រូវទទួលសិក្សាគម្រោងនេះឡើយ ។

**ប្រការ ២៥.-**

ប្រសិនបើសង្កេតឃើញភាពមិនប្រក្រតីនៃផ្នែកណាមួយក្នុងគម្រោងកំពុងសិក្សាឬកំពុងអនុវត្តដែលអាចបង្កមហន្តរាយដល់បរិស្ថានកេរដំណែលប្រវត្តិសាស្ត្រ ឬសាធារណជន ស្ថាបត្យករត្រូវរាយការណ៍ជាបន្ទាន់ដល់អ្នកទទួលខុសត្រូវរបស់ខ្លួនដើម្បីជ្រាប និងមានវិធានការដោះស្រាយ។

**ប្រការ ២៦.-**

ស្ថាបត្យករមិនអាចធ្វើការអធិប្បាយ ឬបង្ហាញកិច្ចការទាំងឡាយណាដែលមិនមែនជាកិច្ចការរបស់ខ្លួនផ្ទាល់ដល់អតិថិជន ឬម្ចាស់គម្រោងជំនួសស្ថាបត្យករដទៃដោយគ្មានការយល់ព្រមពីស្ថាបត្យករនោះឡើយ។

**ប្រការ ២៧.-**

ស្ថាបត្យករមិនត្រូវចុះកិច្ចព្រមព្រៀងជាមួយម្ចាស់គម្រោង ប្រសិនបើយល់ឃើញថាគម្រោងនោះមានផលប៉ះពាល់ដល់កម្មសិទ្ធិបញ្ញាស្ថាបត្យករដទៃទៀត ក្នុងពេលកំពុងបំពេញការងារប្រសិនបើដឹងថាមានផលប៉ះពាល់ដល់កម្មសិទ្ធិបញ្ញាស្ថាបត្យករដទៃទៀតនោះ ស្ថាបត្យករត្រូវផ្អាកជាបន្ទាន់លុះត្រាតែមានដំណោះស្រាយរួចរាល់ទើបអាចបន្តការងារបាន។

**ប្រការ ២៨.-**

ស្ថាបត្យករត្រូវបដិសេធចំពោះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយម្ចាស់គម្រោងប្រសិនបើទំហំការងារ ការទទួលខុសត្រូវ និងកម្រៃសិក្សាគម្រោងមិនមានភាពច្បាស់លាស់។

ប្រការ ២៩.-

ស្ថាបត្យករចាំបាច់ត្រូវផ្តល់ព័ត៌មានជាមុនដល់អតិថិជននូវរាល់បញ្ហាដែលអាចជះឥទ្ធិពលទៅលើសោភ័ណភាព គុណភាព សុវត្ថិភាព បរិស្ថាន តម្លៃ ឬពេលវេលាក្នុងការបំពេញការងារ។

ប្រការ ៣០.-

ស្ថាបត្យករត្រូវរក្សាព័ត៌មានសម្ងាត់ដែលទទួលបានក្នុងពេលប្រតិបត្តិវិជ្ជាជីវៈជំនាញ។ ស្ថាបត្យករមិនត្រូវប្រើប្រាស់ព័ត៌មានដែលទទួលបានដើម្បីធ្វើឲ្យម្ចាស់គម្រោង ឬបុគ្គលដទៃទៀតបាត់បង់ផលប្រយោជន៍ ។ ស្ថាបត្យករអាចបញ្ចេញព័ត៌មានសម្ងាត់ទាំងនេះបាន ក្នុងករណីមានការយល់ព្រមពីម្ចាស់គម្រោងជាលាយលក្ខណ៍អក្សរតាមការតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៣១.-

ស្ថាបត្យករត្រូវបដិសេធក្នុងការបំពេញការងារជំនាញប្រសិនបើតម្រូវការរបស់ម្ចាស់គម្រោងមិនស្របតាមនគរូបនីយប្បញ្ញត្តិ បទដ្ឋានបច្ចេកទេស និងក្រមសីលធម៌របស់ស្ថាបត្យករ ។

ប្រការ ៣២.-

ស្ថាបត្យករត្រូវរក្សាអព្យាក្រឹតភាពលើវិជ្ជាជីវៈជំនាញរបស់ខ្លួនគ្រប់កាលៈទេសៈនិងត្រូវចៀសវាងអំពើដែលផ្តល់ផលប្រយោជន៍ដល់អ្នកសាងសង់ដែលប៉ះពាល់ផលប្រយោជន៍ម្ចាស់គម្រោង ឬអ្នកពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី៦
## ទណ្ឌកម្មខាងវិន័យ

ប្រការ ៣៣.-

ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី គ.ស.ក. នៃព្រះរាជាណាចក្រកម្ពុជាដែលបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ស្ថាបត្យករនេះត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៣១នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា។

ប្រការ ៣៤.-

ស្ថាបត្យករដែលបានចុះឈ្មោះក្នុងបញ្ជី គ.ស.ក. នៃព្រះរាជាណាចក្រកម្ពុជាដែលបានផ្តល់ព័ត៌មានឬរបាយការណ៍មិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ដោយចេតនាជូនអគ្គលេខាធិការដ្ឋាន នៃគណៈស្ថាបត្យករកម្ពុជាត្រូវទទួលទណ្ឌកម្មខាងវិន័យ។

**ប្រការ ៣៥.-**

ជនទាំងឡាយណាដែលក្លែងបន្លំជាស្ថាបត្យករ ដែលបានចុះឈ្មោះក្នុងបញ្ជី គ.ស.ក. ត្រូវទទួលទោសតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៧
## អវសានបញ្ញត្តិ

**ប្រការ ៣៦.-**

នៅពេលសុំចុះឈ្មោះក្នុងបញ្ជីគណៈស្ថាបត្យករកម្ពុជា ស្ថាបត្យករទាំងអស់ត្រូវគោរពតាមក្រមសីលធម៌ស្ថាបត្យករនេះ។

**ប្រការ ៣៧.-**

ស្ថាបត្យករត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេសនៃជំនាញស្ថាបត្យកម្មដែលបានកំណត់ជាផ្លូវការ ។

**ប្រការ ៣៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣៩.-**

សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៣

**ប្រធានក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា**

គ.ស.ក

**ឌឹម ឈុនលឹម**